**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

PHNOM PENH WATER SUPPLY AUTHORITY

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

# សេចក្តីប្រកាសព័ត៌មាន

**ស្តីពី**

**ការកែតម្រូវព័ត៌មាននៃ របាយការណ៍ហិរញ្ញវត្ថុ**
**សង្ខេបចន្លោះពេលសម្រាប់ដំណាច់ការិយបរិច្ឆេទ ៣ខែ ដែលបានបញ្ចប់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៦**
**និងរបាយការណ៍របស់សវនករឯករាជ្យ ស្តីពីការត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុ**

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រ.ទ.ស.ភ) សូមជម្រាបជូនវិនិយោគិន និងសាធារណជនទាំងអស់ជ្រាបថា៖ រ.ទ.ស.ភ សូមធ្វើការកែតម្រូវព័ត៌មានចំនួន **២ ចំណុច** ដូចខាងក្រោម ទៅលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលសម្រាប់ដំណាច់ការិយបរិច្ឆេទ ៣ខែ ដែលបានបញ្ចប់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៦ និងរបាយការណ៍របស់សវនករឯករាជ្យស្តីពីការត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុ ដែលបានផ្សព្វផ្សាយជាសាធារណៈ កាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៦ ជាឯកសារគាំទ្រក្នុងការបង្ហាញព័ត៌មានទាន់ពេលស្តីពីការកើនឡើងចំណេញសុទ្ធក្នុងត្រីមាសទី១ ឆ្នាំ២០២៦ ជាភាសាខ្មែរ និងអង់គ្លេស។ របាយការណ៍នេះស្ថិតក្នុងផ្នែកទី៣ និងជាឧបសម្ព័ន្ធទី១ នៃរបាយការណ៍ប្រចាំត្រីមាសទី១ ឆ្នាំ២០២៦ ដែលបានផ្សព្វផ្សាយជាសាធារណៈ កាលពីថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២៦ ជាភាសាខ្មែរ និងអង់គ្លេស៖

| **ព័ត៌មានមុនកែតម្រូវ** | **ព័ត៌មានក្រោយកែតម្រូវ** |
|---|---|
| **ផ្នែកទី៣ : របាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ**<br>ឧបសម្ព័ន្ធទី១: របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលសម្រាប់ដំណាច់ការិយបរិច្ឆេទ ៣ខែ ដែលបានបញ្ចប់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៦ និងរបាយការណ៍របស់សវនករឯករាជ្យ ស្តីពីការត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុ<br>➢ កំណត់សម្គាល់ ១. ព័ត៌មានអំពី រ.ទ.ស.ភ (របាយការណ៍ភាសាអង់គ្លេស ទំព័រទី១១) | |
| Srah Cbork | Srah Chork |
| ➢ កំណត់សម្គាល់ ២០.ការរាយការណ៍ឡើងវិញនៃព័ត៌មានប្រៀបធៀប (របាយការណ៍ភាសាខ្មែរ ទំព័រទី៣២)<br>គ. ការបង្ហាញការ(ខាត)/ចំណេញពីការប្តូររូបិយប័ណ្ណបរទេស | |
| រ.ទ.ស.ភ បានសម្រេចជ្រើសរើសយកការដាលទ្ធផលសម្រាប់ដំណាច់ការិយបរិច្ឆេទ៣ខែ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៥ ចំណូលត្រូវបង្ហាញលើសចំនួន ៣.៣៧០ពាន់រៀល ហើយចំណូល/ចំណាយហិរញ្ញវត្ថុសុទ្ធ ត្រូវបង្ហាញខ្វះចំនួន ៣.៣៧០ពាន់រៀល។ | រ.ទ.ស.ភ បានសម្រេចជ្រើសយក**ការបង្ហាញប្រាក់(ខាត)/ចំណេញពីការប្តូររូបិយប័ណ្ណបរទេសសុទ្ធក្រោមធាតុ“ចំណូល/ចំណាយហិរញ្ញប្បទានសុទ្ធ”**។ ជាលទ្ធផលសម្រាប់ដំណាច់ការិយបរិច្ឆេទ៣ខែ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៥ ចំណូលត្រូវបង្ហាញលើសចំនួន ៣.៣៧០ពាន់រៀល ហើយចំណូល/ចំណាយហិរញ្ញវត្ថុសុទ្ធ ត្រូវបង្ហាញខ្វះចំនួន ៣.៣៧០ពាន់រៀល។ |

អាស្រ័យហេតុនេះ សូមវិនិយោគិន និងសាធារណជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃសៅរ៍ ៤ កើត ខែទុតិយាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៦

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

អគារ៤៥ ផ្លូវ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ: (៨៥៥) ៣១ ៩៣៥ ៨០ ៨០ Email: admin@ppwsa.com.kh

# Phnom Penh Water Supply Authority

## Notes to the condensed interim financial statements for the three-month period ended 31 March 2026

## 1. Corporate information

Phnom Penh Water Supply Authority ("PPWSA") is under the technical supervision of the Ministry of industry, Science, Technology and Innovation ("MISTI") and the financial supervision of the Ministry of the Economy and Finance ("MoEF"), and has its headquarter in Phnom Penh. PPWSA is acknowledged as having the economic characteristics of a public enterprise by the Ministry of Commerce under the registration number Co.0839 Et/2012, dated 27 March 2012.

The registered office of PPWSA is Office 45, Street 106, Sangkat Srah Chork, Khan Daun Penh, Phnom Penh, the Kingdom of Cambodia.

This condensed interim financial statements is presented in Khmer Riel ("KHR"), which is also the functional currency of PPWSA.

***Principal activities***

The principal activities of PPWSA are to process and distribute water for general use by the public in the city of Phnom Penh and surrounding areas, including Takmao, Tbong Khmom and Mlech and the provision of other related services. The objectives of PPWSA are to:

- Invest in, build, enlarge, operate, repair and maintain the means of water sanitation and distribution;
- Manage devices to increase water production, and improve services and water quality to meet demand;
- Operate the business, services and related duties for water supply in accordance with the Board of Director's resolutions and the laws of Cambodia;
- Cooperate with local and external development partners on technology, trade and finance in order to improve and develop PPWSA in accordance with government policy; and
- Ensure sustainable production processes, business and finance for the public interest.

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
## សម្រាប់ដំណាច់ការិយបរិច្ឆេទ ៣ខែ ដែលបានបញ្ចប់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៦

## ២០. ការរាយការណ៍ឡើងវិញនៃព័ត៌មានប្រៀបធៀប (ត)

### គ. ការបង្ហាញការ(ខាត)/ចំណេញពីការប្តូររូបិយប័ណ្ណបរទេស

រ.ទ.ស.ភ. បានបង្ហាញនូវប្រាក់(ខាត)/ចំណេញពីការប្តូររូបិយប័ណ្ណបរទេស ក្នុងធាតុផ្សេងៗរួមមាន ចំណូល និង ចំណូល/ចំណាយហិរញ្ញប្បទានសុទ្ធ ក្នុងរបាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ។ បន្ទាប់ពីបាន ពិនិត្យលើគោលនយោបាយនៃការបង្ហាញព័ត៌មានគណនេយ្យ រ.ទ.ស.ភ. បានសម្រេចជ្រើសយកការបង្ហាញប្រាក់(ខាត)/ចំណេញពីការប្តូររូបិយប័ណ្ណបរទេសសុទ្ធ ក្រោមធាតុ"ចំណូល/ចំណាយហិរញ្ញប្បទានសុទ្ធ"។ ជាលទ្ធផល សម្រាប់ដំណាច់ការិយបរិច្ឆេទ ៣ខែ ដែលបានបញ្ចប់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៥ ចំណូលត្រូវបានបង្ហាញ លើសចំនួន ៣.៣៧០ ពាន់រៀល ហើយចំណូល/ចំណាយហិរញ្ញប្បទានសុទ្ធត្រូវបង្ហាញខ្វះចំនួន ៣.៣៧០ ពាន់រៀល។

### ឃ. ការបង្ហាញក្នុងរបាយការណ៍លំហូរទឹកប្រាក់

រ.ទ.ស.ភ. បានរកឃើញកំហុសជាច្រើនក្នុងប្រមាណវិធីគណនា សម្រាប់ការបង្ហាញក្នុងរបាយការណ៍លំហូរទឹកប្រាក់ សម្រាប់ដំណាច់ការិយបរិច្ឆេទ ៣ខែ ដែលបានបញ្ចប់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៥ ដូចខាងក្រោម៖

- សាច់ប្រាក់សុទ្ធទទួលបានពីសកម្មភាពប្រតិបត្តិការ បានបង្ហាញលើសចំនួន ៧.០៨៣.៣៨៩ ពាន់រៀល
- សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ បានបង្ហាញលើសចំនួន ៧.២៧១.៣៩៧ ពាន់រៀល និង
- សាច់ប្រាក់សុទ្ធទទួលបានពីសកម្មភាពហិរញ្ញប្បទាន បានបង្ហាញលើសចំនួន ១៨៨.០០៨ ពាន់រៀល។

ប្រតិបត្តិការសារវន្តដែលមិនមែនជាសាច់ប្រាក់ពីសកម្មភាពវិនិយោគ ត្រូវបានបង្ហាញលើសចំនួន ២៩.០៦៨.៦៣៩ ពាន់រៀល។ កំហុសឆ្គងទាំងនេះ ពុំមានផលប៉ះពាល់ដល់សមតុល្យសាច់ប្រាក់ និងសាច់ប្រាក់សមមូលឡើយ។

### ង. ប្រាក់ចំណេញក្នុងមួយភាគហ៊ុន

ជាលទ្ធផល នៃចំណុច ក ខាងលើ ប្រាក់ចំណេញក្នុងមួយភាគហ៊ុនគោល និងប្រាក់ចំណេញក្នុងមួយភាគហ៊ុនថយចុះ សម្រាប់ដំណាច់ការិយបរិច្ឆេទ ៣ខែ ដែលបានបញ្ចប់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៥ ត្រូវបានធ្វើនិយ័តកម្មព្រមគ្នាទៅចំនួន ២៦០,៩៥ ពាន់រៀលក្នុងមួយហ៊ុន។